*Unofficial Translation*

No. SM 23/2025 MFA.IC

**Statement**

**of the Spokesperson of the Ministry of Foreign Affairs and International Cooperation**

# Cambodia Reaffirms Its Determination to Combat All Forms of Transnational Crimes

The Royal Government of Cambodia reaffirms its strong commitment to combating and suppressing all forms of transnational crimes, including online scam, human trafficking and other cyber-enabled offenses that threaten the safety, dignity, and welfare of individuals.

Under the leadership of **Samdech Thipadei Hun Manet**, Prime Minister of the Kingdom of Cambodia, the Cambodian competent authorities have made significant achievement in dismantling criminal networks and bringing perpetrators to justice.

## Recognizing the Complexity of the Challenge

Online crime today is increasingly **transnational and technologically sophisticated**. Criminal networks operate across multiple jurisdictions, exploiting encrypted communications, digital currencies, and transnational recruitment chains that make the difference between victims and perpetrators less clear. Many individuals trapped in scam compounds are themselves victims of trafficking and coercion.

Cambodia stresses the importance of **distinguishing genuine victims from criminals**, ensuring that responses are **humane, proportionate, and just**. We also underscore that **sensational or misleading narratives** can unfairly stigmatize workers and migrant communities. Cambodia therefore calls for **responsible and factual communication** that supports law enforcement while protecting vulnerable populations.

## Measures Undertaken and Tangible Results in the Fight Against Online Crimes

Over the past two years, Cambodia has intensified nationwide operations to identify, investigate, and dismantle online scam networks. These efforts include:

- Strengthening and enforcing laws against trafficking, cybercrime, fraud, and money laundering, while updating regulations on digital evidence and asset recovery.
- Enhancing inter-agency coordination among the competent authorities.
- Conducting targeted inspections, raids, and arrests of ringleaders and facilitators, while seizing criminal assets such as cash, cryptocurrencies, vehicles, and properties.
- Expanding 24/7 hotlines and shelters, providing psychosocial, medical, and legal support to victims, and ensuring the non-criminalization of coerced victims.

The Government has further **enhanced its legal and institutional frameworks**, strengthened inter-agency coordination, and enacted updates to laws on cybercrime, anti-money laundering, and human trafficking.

The Government is implementing stronger cyber-crime prevention measures, including new inter-ministerial coordination mechanisms, enhanced digital surveillance, and the suspension of websites and business licenses linked to illegal operations.

The Government has also taken decisive administrative actions, including the revocation of 120 business licenses, suspension of over 1,000 gambling-related websites, and freezing of illicit bank accounts linked to digital fraud schemes. Enhanced cooperation with foreign embassies has facilitated the identification and repatriation of victims, as well as the exchange of intelligence on regional cyber-criminal groups.

The Cambodian law enforcement agencies have conducted numerous targeted operations across the country. These actions have led to the **closure of multiple illegal compounds**, the **arrest of hundreds of suspects**, and the **rescue and protection of Cambodian and foreign victims** of online exploitation.

Moving forward, Cambodia is establishing a national cyber-crime task force, upgrading digital-forensics capacity, and working with all partners to strengthen cross-border enforcement and cyber-governance frameworks. These results underscore Cambodia's firm commitment to eradicating online crimes, safeguarding digital integrity, and promoting a safer regional cyberspace.

### Strengthening International Cooperation

Cambodia continues to work closely with its **regional and international partners**, including the **Republic of Korea, China, and ASEAN member states**, through **joint investigations, intelligence sharing, and mutual legal assistance**. These partnerships have produced tangible results—such as the disruption of major scam operations, successful prosecutions of organized crime figures, and the repatriation of foreign victims to their home countries.

At the same time, Cambodia calls on international media and stakeholders to ensure **accurate, fair, and evidence-based reporting** that promotes cooperation rather than division.

### Cambodia and the Republic of Korea: A Shared Commitment

The Ministry expresses its **deep regret and condolences** regarding the recent tragic incidents involving Korean nationals who have fallen victim to online employment scams and related crimes in Cambodia. The Royal Government of Cambodia conveys its heartfelt sympathy to the families of the victims, and to the Government and people of the Republic of Korea.

During the recent meeting between **Samdech Thipadei Hun Manet** and **Her Excellency Kim Jina**, Second Vice Minister of Foreign Affairs of the Republic of Korea, both sides reaffirmed their shared commitment to combating transnational crimes, particularly online scams. The Prime Minister praised the **fruitful cooperation** between Cambodia and Korea and expressed readiness to strengthen joint efforts to prevent, suppress, and dismantle criminal networks more effectively.

Samdech Prime Minister emphasized that the two countries possess the necessary capacity and mechanisms to address these issues bilaterally, reaffirming that the partnership is rooted in mutual respect, equality, and trust. Cambodia welcomes continued dialogue and cooperation with the Republic of Korea to advance shared goals for regional stability, security, and prosperity.

Vice Minister Kim Jina also held discussions with senior officials from both the Ministry of Interior and the Ministry of Foreign Affairs on future cooperation between the two countries in their joint efforts to combat all forms of online crime. She was subsequently briefed on the measures undertaken and the significant results achieved in the fight against such crimes.

## Future Cooperation

Looking ahead, Cambodia will continue to strengthen **law enforcement capacity, legislative frameworks, and regional partnerships** under the ASEAN framework. The Kingdom will sustain its enforcement momentum through expanded inspections, stronger financial-crime taskforces, and enhanced public awareness campaigns.

**Cambodia's message is clear:** "Criminals exploit technology and borders; our response must be equally connected and coordinated." Through **cooperation—not blame—** the Kingdom of Cambodia will continue to pursue kingpins, protect victims, and preserve peace, order, and dignity for all.

Phnom Penh, 23 October 2025

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ

លេខៈ ៥ក ២៣/២០២៥ កបទ.សអ

# សេចក្តីថ្លែងការណ៍
# របស់អ្នកនាំពាក្យក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
# កម្ពុជាបញ្ជាក់ជាថ្មីពីការប្តេជ្ញាចិត្តប្រយុទ្ធប្រឆាំងឧក្រិដ្ឋកម្មឆ្លងដែនគ្រប់ទម្រង់

រាជរដ្ឋាភិបាលកម្ពុជា សូមបញ្ជាក់ជាថ្មីពីការប្តេជ្ញាចិត្តយ៉ាងមុតមាំក្នុងការប្រយុទ្ធប្រឆាំង និងបង្ក្រាបឧក្រិដ្ឋកម្មឆ្លងដែនគ្រប់ទម្រង់ រួមទាំងការឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា ការជួញដូរមនុស្ស និងបទល្មើសតាមប្រព័ន្ធបច្ចេកវិទ្យាផ្សេងទៀត ដែលគំរាមកំហែងដល់សុវត្ថិភាព សេចក្តីថ្លៃថ្នូរ និងសុខុមាលភាពបុគ្គល។

ក្រោមការដឹកនាំរបស់**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា អាជ្ញាធរមានសមត្ថកិច្ចកម្ពុជាសម្រេចបានសមិទ្ធផលសំខាន់ៗជាច្រើនក្នុងការបង្ក្រាបបណ្តាញឧក្រិដ្ឋជន និងនាំខ្លួនជនល្មើសមកផ្តន្ទាទោស។

## ការទទួលស្គាល់ភាពស្មុគស្មាញនៃបញ្ហាប្រឈម

ឧក្រិដ្ឋកម្មតាមប្រព័ន្ធបច្ចេកវិទ្យាបច្ចុប្បន្ន កំពុងរីករាលដាលកាន់តែខ្លាំងឡើងដោយឆ្លងកាត់ព្រំដែនប្រទេស ហើយប្រើប្រាស់បច្ចេកវិទ្យាកាន់តែទំនើប។ បណ្តាញឧក្រិដ្ឋកម្មទាំងនោះ ធ្វើប្រតិបត្តិការឆ្លងដែនសមត្ថកិច្ចផ្សេងគ្នាជាច្រើន ប្រើប្រាស់សារទាក់ទងសម្ងាត់ (តាមរយៈកូដនីយកម្ម) រូបិយប័ណ្ណឌីជីថល និងខ្សែសង្វាក់ជ្រើសរើសពលកម្មឆ្លងប្រទេស ដែលធ្វើអោយពិបាកបែងចែកពីភាពខុសគ្នារវាងជនរងគ្រោះ និងជនប្រព្រឹត្តបទល្មើស។ បុគ្គលជាច្រើនរូបដែលជាប់នៅក្នុងទីតាំងឆបោក គឺជាជនរងគ្រោះនៃអំពើជួញដូរ និងការបង្ខិតបង្ខំ។

កម្ពុជាសង្កត់ធ្ងន់លើសារៈសំខាន់នៃការបែងចែកអោយដាច់រវាងជនរងគ្រោះពិតប្រាកដ និងឧក្រិដ្ឋជន ដោយធានាថា វិធានការឆ្លើយតបនានា មានលក្ខណៈមនុស្សធម៌ សមាមាត្រ និងយុត្តិធម៌។ យើងក៏សូមគូសបញ្ជាក់ផងដែរថា ព័ត៌មានបំផ្លើសឬបំភ័ន្ត អាចបង្កអោយមានការមាក់ងាយយ៉ាងអយុត្តិធម៌ទៅលើពលករ និងអ្នកចំណាកស្រុកធ្វើការងារ។ ហេតុដូចនេះ កម្ពុជាសូមអំពាវនាវឱ្យមានការផ្សព្វផ្សាយព័ត៌មានប្រកបដោយការទទួលខុសត្រូវនិងភាពពិតប្រាកដ ដែលគាំទ្រដល់ការអនុវត្តច្បាប់ ហើយការពារជនដែលងាយរងគ្រោះ។



អាសយដ្ឋានៈ លេខ ៣ វិថី សម្តេច ហ៊ុន សែន
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : (855) 23 216 122
ទូរសារ : (855) 23 216 141, 023 213 341
អ៊ីម៉ែលៈ mfaic@mfaic.gov.kh

### វិធានការកំពុងអនុវត្ត និងលទ្ធផលជាក់ស្តែងក្នុងការប្រយុទ្ធប្រឆាំងនឹងឧក្រិដ្ឋកម្មតាមប្រព័ន្ធបច្ចេកវិទ្យា

ក្នុងរយៈពេលពីរឆ្នាំកន្លងមកនេះ កម្ពុជាបានបង្កើនប្រតិបត្តិការទូទាំងប្រទេសដើម្បីកំណត់មុខសញ្ញា ស៊ើបអង្កេត និងបង្ក្រាបបណ្តាញឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា។ កិច្ចខិតខំប្រឹងប្រែងទាំងនេះរួមមាន៖

- ការពង្រឹង និងអនុវត្តច្បាប់ប្រឆាំងនឹងការជួញដូរ ឧក្រិដ្ឋកម្មតាមប្រព័ន្ធបច្ចេកវិទ្យា ការឆបោក និងការសំអាតប្រាក់ ព្រមទាំងការធ្វើបច្ចុប្បន្នកម្មលើបទប្បញ្ញត្តិស្តីពីភស្តុតាងឌីជីថល និងការស្វែងរកទ្រព្យសម្បត្តិ។
- បង្កើនការសម្របសម្រួលអន្តរស្ថាប័នក្នុងចំណោមអាជ្ញាធរមានសមត្ថកិច្ច។
- អនុវត្តការត្រួតពិនិត្យគោលដៅ ចុះឆែកឆេរ និងចាប់ខ្លួនមេខ្លោង និងអ្នកសមគំនិត ព្រមទាំងរឹបអូសទ្រព្យសម្បត្តិឧក្រិដ្ឋកម្ម ដូចជាសាច់ប្រាក់ រូបិយបណ្ណគ្រីបតូ យានយន្ត និងអចលនទ្រព្យ។
- ពង្រីកបណ្តាញទូរស័ព្ទទាន់ហេតុការណ៍២៤ម៉ោង/ថ្ងៃ និង៧ថ្ងៃ/សប្តាហ៍ និងទីជំរកបណ្តោះអាសន្ន ផ្តល់ជំនួយផ្នែកផ្លូវចិត្ត វេជ្ជសាស្ត្រ និងផ្លូវច្បាប់ដល់ជនរងគ្រោះ និងធានាការមិនដាក់ទោសទណ្ឌទៅលើជនរងគ្រោះដែលត្រូវបានគេបង្ខិតបង្ខំ។

រាជរដ្ឋាភិបាលបានពង្រឹងបន្ថែមទៀតនូវក្របខណ្ឌច្បាប់និងស្ថាប័នរបស់ខ្លួន ពង្រឹងការសម្របសម្រួលអន្តរស្ថាប័ន និងបានធ្វើបច្ចុប្បន្នកម្មលើច្បាប់ស្តីពីឧក្រិដ្ឋកម្មតាមប្រព័ន្ធបច្ចេកវិទ្យា ការប្រឆាំងការសំអាតប្រាក់ និងការជួញដូរមនុស្ស។

រាជរដ្ឋាភិបាលកំពុងអនុវត្តវិធានការទប់ស្កាត់កាន់តែខ្លាំងក្លាចំពោះឧក្រិដ្ឋកម្មតាមប្រព័ន្ធបច្ចេកវិទ្យា រួមទាំងយន្តការសម្របសម្រួលអន្តរក្រសួងថ្មី ការពង្រឹងការឃ្លាំមើលតាមប្រព័ន្ធឌីជីថល និងការផ្អាកដំណើរការគេហទំព័រ និងអាជ្ញាប័ណ្ណអាជីវកម្មដែលពាក់ព័ន្ធនឹងប្រតិបត្តិការខុសច្បាប់។

រាជរដ្ឋាភិបាល ក៏បានចាត់វិធានការរដ្ឋបាលយ៉ាងម៉ឺងម៉ាត់ រួមទាំងការដកហូតអាជ្ញាប័ណ្ណអាជីវកម្មចំនួន ១២០ ការផ្អាកគេហទំព័រទាក់ទងនឹងល្បែងជាង១៣ពាន់ និងការបង្កកគណនីធនាគារខុសច្បាប់ដែលភ្ជាប់ទៅនឹងផែនការឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា។ ការពង្រឹងកិច្ចសហប្រតិបត្តិការជាមួយស្ថានទូតបរទេស បានជួយសម្រួលដល់ការកំណត់អត្តសញ្ញាណ និងការធ្វើមាតុភូមិនិវត្តន៍ជនរងគ្រោះ ក៏ដូចជាការផ្លាស់ប្តូរព័ត៌មានសម្ងាត់អំពីក្រុមប្រព្រឹត្តឧក្រិដ្ឋតាមប្រព័ន្ធបច្ចេកវិទ្យាក្នុងតំបន់ផងដែរ។

ភ្នាក់ងារអនុវត្តច្បាប់របស់កម្ពុជា បានធ្វើប្រតិបត្តិការតាមគោលដៅជាច្រើននៅទូទាំងប្រទេស។ ប្រតិបត្តិការទាំងនោះ បានឈានទៅដល់ការបិទទីតាំងខុសច្បាប់ជាច្រើនកន្លែង ការចាប់ខ្លួនជនសង្ស័យរាប់រយនាក់ និងការជួយសង្គ្រោះនិងការពារជនរងគ្រោះកម្ពុជានិងបរទេសពីការកេងប្រវ័ញ្ចតាមប្រព័ន្ធបច្ចេកវិទ្យា។

សម្រាប់ពេលអនាគត កម្ពុជាកំពុងរៀបចំបង្កើតក្រុមការងារបង្ក្រាបឧក្រិដ្ឋកម្មតាមប្រព័ន្ធបច្ចេកវិទ្យាថ្នាក់ជាតិ បង្កើនសមត្ថភាពធ្វើកោសល្យវិច្ច័យឌីជីថល និងបន្តសហការជាមួយដៃគូទាំងអស់ ដើម្បីពង្រឹងក្របខ័ណ្ឌការអនុវត្តច្បាប់ឆ្លងព្រំដែន និងអភិបាលកិច្ចនៃប្រព័ន្ធបច្ចេកវិទ្យា។ លទ្ធផលទាំងនេះ បញ្ជាក់ពីការប្តេជ្ញាចិត្តយ៉ាងមុតមាំរបស់កម្ពុជាក្នុងការលុបបំបាត់ឧក្រិដ្ឋកម្មតាមប្រព័ន្ធបច្ចេកវិទ្យា ការពារសុចរិតភាពនៃប្រព័ន្ធឌីជីថល និងលើកកម្ពស់បណ្តាញបច្ចេកវិទ្យាក្នុងតំបន់ដែលមានសុវត្ថិភាពជាងមុន។

## ការពង្រឹងកិច្ចសហប្រតិបត្តិការអន្តរជាតិ

កម្ពុជាបាននិងកំពុងបន្តធ្វើការងារយ៉ាងជិតស្និទ្ធជាមួយដៃគូក្នុងតំបន់ និងលើឆាកអន្តរជាតិ រួមទាំងសាធារណរដ្ឋកូរ៉េ ប្រទេសចិន និងរដ្ឋសមាជិកអាស៊ាន តាមរយៈការស៊ើបអង្កេតរួមគ្នា ការចែករំលែកព័ត៌មានសម្ងាត់ និងការផ្តល់ជំនួយផ្នែកច្បាប់ទៅវិញទៅមក។ ភាពជាដៃគូទាំងអស់នេះ នាំអោយសម្រេច នូវលទ្ធផលជាក់ស្តែងជាច្រើន ដូចជាការទប់ស្កាត់ចំពោះក្រុមប្រតិបត្តិការឆបោកធំៗ ការកាត់ទោសក្រុមឧក្រិដ្ឋជនដែលមានបណ្តាញចាត់តាំង រួមទាំងការបញ្ជូនជនរងគ្រោះបរទេសត្រឡប់ទៅមាតុប្រទេសរបស់ពួកគេវិញ។

ទន្ទឹមនេះ កម្ពុជាសូមទទូចដល់ប្រព័ន្ធផ្សព្វផ្សាយអន្តរជាតិ និងភាគីពាក់ព័ន្ធទាំងអស់ មេត្តាជានាបាននូវការរាយការណ៍ទាំងឡាយប្រកបដោយសុក្រឹតភាព យុត្តិធម៌ និងផ្អែកលើភស្តុតាង ក្នុងស្មារតីលើកស្ទួយកិច្ចសហប្រតិបត្តិការ ជាជាងការបំបែកបំបាក់។

## កម្ពុជា និងសាធារណរដ្ឋកូរ៉េ៖ ការប្តេជ្ញាចិត្តរួមគ្នា

ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ សូមសម្តែងការសោកស្តាយ និងសមានទុក្ខជ្រាលជ្រៅចំពោះសោកនាដកម្មថ្មីៗនេះ ពាក់ព័ន្ធនឹងពលរដ្ឋកូរ៉េ ដែលជាជនរងគ្រោះក្នុងអំពើឆបោកការងារតាមប្រព័ន្ធបច្ចេកវិទ្យា និងក្នុងបទល្មើសពាក់ព័ន្ធផ្សេងទៀតនៅកម្ពុជា។ រដ្ឋាភិបាលកម្ពុជា សូមសម្តែងសមានចិត្តយ៉ាងជ្រាលជ្រៅជូនចំពោះក្រុមគ្រួសារជនរងគ្រោះ និងចំពោះរដ្ឋាភិបាល និងប្រជាជននៃសាធារណរដ្ឋកូរ៉េផងដែរ។

ក្នុងឱកាសជំនួបថ្មីៗនេះ រវាង**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី** និងលោកជំទាវ **គីម ជីណា** (Kim Jina) អនុរដ្ឋមន្ត្រីទី២នៃក្រសួងការបរទេសសាធារណរដ្ឋកូរ៉េ **សម្តេចធិបតី** និងលោកជំទាវបានបញ្ជាក់ជាថ្មីនូវការប្តេជ្ញាចិត្តរួមគ្នាក្នុងការប្រយុទ្ធប្រឆាំងនឹងឧក្រិដ្ឋកម្មឆ្លងដែន ជាពិសេសការឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា។ **សម្តេចធិបតី** បានសរសើរចំពោះកិច្ចសហប្រតិបត្តិការប្រកបដោយផ្លែផ្ការវាងកម្ពុជា និងសាធារណរដ្ឋកូរ៉េ ព្រមទាំងបង្ហាញការត្រៀមខ្លួនជាស្រេចរបស់កម្ពុជា ដើម្បីបន្តពង្រឹងកិច្ចខិតខំប្រឹងប្រែងរួមគ្នាក្នុងការបង្ការ ទប់ស្កាត់ និងបង្ក្រាបបណ្តាញឧក្រិដ្ឋកម្ម ឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់។

**សម្តេចធិបតីនាយករដ្ឋមន្ត្រី** បានសង្កត់ធ្ងន់ថា ប្រទេសទាំងពីរមានសមត្ថភាព និងលទ្ធភាពគ្រប់គ្រាន់ ដើម្បីដោះស្រាយបញ្ហាទាំងនេះ ជាទ្វេភាគី ដោយ**សម្តេច** បញ្ជាក់ជាថ្មីថា ភាពជាដៃគូនេះ ស្តែងចេញតាមរយៈការគោរពគ្នាទៅវិញទៅមក សមភាព និងការជឿទុកចិត្ត។ កម្ពុជាស្វាគមន៍ចំពោះកិច្ចសន្ទនា និងកិច្ចសហប្រតិបត្តិការជាបន្តទៀតជាមួយសាធារណរដ្ឋកូរ៉េ ដើម្បីជំរុញគោលដៅរួមគ្នាសម្រាប់ស្ថិរភាព សន្តិសុខ និងវិបុលភាពក្នុងតំបន់។

លោកជំទាវអនុរដ្ឋមន្ត្រី ក៏បានចូលជួបពិភាក្សាជាមួយមន្ត្រីជាន់ខ្ពស់មកពីក្រសួងមហាផ្ទៃ និងក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិផងដែរ ដោយលើកឡើងពីកិច្ចសហប្រតិបត្តិការនាពេលអនាគតរវាងប្រទេសទាំងពីរក្នុងកិច្ចខិតខំប្រឹងប្រែងរួមគ្នាប្រយុទ្ធប្រឆាំងនឹងឧក្រិដ្ឋកម្មតាមប្រព័ន្ធបច្ចេកវិទ្យាគ្រប់ទម្រង់។ ក្នុងឱកាសនោះ លោកជំទាវ ត្រូវបានជម្រាបជូនផងដែរអំពីវិធានការនានាដែលត្រូវបានអនុវត្ត ក៏ដូចជាលទ្ធផលសំខាន់ៗសម្រេចបាននៅក្នុងការប្រយុទ្ធប្រឆាំងនឹងឧក្រិដ្ឋកម្មទាំងនេះ។

**កិច្ចសហប្រតិបត្តិការនាពេលអនាគត**

សម្រាប់ទិសដៅទៅមុខ កម្ពុជានឹងបន្តពង្រឹងសមត្ថភាពអនុវត្តច្បាប់ ក្របខ័ណ្ឌច្បាប់ និងភាពជាដៃគូក្នុងតំបន់ក្រោមក្របខ័ណ្ឌអាស៊ាន។ កម្ពុជា ក៏នឹងបន្តរក្សាភាពសកម្មនៃការអនុវត្តការងាររបស់ខ្លួនផងដែរ តាមរយៈសកម្មភាពស៊ើបអង្កេតដែលមានវិសាលភាពកាន់តែទូលំទូលាយ ការពង្រឹងក្រុមការងារប្រឆាំងឧក្រិដ្ឋកម្ម កាន់តែរឹងមាំ និងការជំរុញយុទ្ធនាការបញ្ជ្រាបការយល់ដឹងជាសាធារណៈ កាន់តែប្រសើរ។

**សាររបស់កម្ពុជាគឺច្បាស់លាស់៖** «ខណៈដែលឧក្រិដ្ឋជនយកបច្ចេកវិទ្យា និងព្រំដែនជាឈ្នាន់ វិធានការឆ្លើយតបរបស់យើងប្រឆាំងនឹងឧក្រិដ្ឋកម្មទាំងនោះ ចាំបាច់ត្រូវធ្វើឡើងដូចគ្នា ក្រោមកិច្ចសហការ និងការសម្របសម្រួល»។ តាមរយៈកិច្ចសហប្រតិបត្តិការ មិនមែនការស្តីបន្ទោស ព្រះរាជាណាចក្រកម្ពុជានឹងបន្តស្វែងរកឧក្រិដ្ឋជន ការពារនិងសង្គ្រោះជនរងគ្រោះ ព្រមទាំងរក្សាសុខសុវត្ថិភាព សណ្តាប់ធ្នាប់សង្គម និងសេចក្តីថ្លៃថ្នូររបស់មនុស្សគ្រប់ៗគ្នា៕

ថ្ងៃព្រហស្បតិ៍ ២កើត ខែកត្តិក ឆ្នាំម្សាញ់ ពស ២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី២៣ ខែតុលា ឆ្នាំ២០២៥